# សេចក្ដីអញ្ជើញរបស់យើងខ្ញុំចំពោះលោកអ្នក



យើងមានចិត្តរីករាយនឹងនិយាយជាមួយលោកអ្នកតាមសន្លឹកនៃសៀវភៅស្ដើងនេះ ។
យើងសង្ឃឹមថាលោកអ្នកមានចិត្តរីករាយនឹងរៀនថែមទៀតអំពីស្មរបន្ទាល់ព្រះយេហូវ៉ា ។
យើងសូមអញ្ជើញលោកអ្នកមកប្រូបរួមជាមួយនឹងយើងនៅឯសាលព្រះរាជាណាចក្ររបស់យើងដែលនៅជិតទីលំនៅអ្នក ។
សូមអញ្ជើញមកទស្សនានូវដំណើរការប្រជុំរបស់យើង ។
ហើយមកទស្សនាផងដែរ
នូវរបៀបដែលយើងខ្ញុំខំប្រឹងប្រែងចែកដំណឹងល្អនៃផែនដីជាសួនមនោរម្យនៅក្រោមព្រះរាជាណាចក្ររបស់ព្រះគ្រិស្ទជាមួយនឹងអ្នកដទៃទៀតផង ។

ព្រះទ្រង់បានបន្ទូលថា: «តែតាមសេចក្ដីសន្យារបស់ទ្រង់ នោះយើងរាល់គ្នាទន្ទឹងចាំផ្ទៃមេឃថ្មី នឹងផែនដីថ្មីដែលមានសុទ្ធតែសេចក្ដីសុចរិតវិញ» ។ (ពេត្រុសទី២ ៣:១៣) ជាច្រើនសតវត្សបានកន្លងទៅហើយ ។ ពេលវេលារង់ចាំជិតដល់ទីបញ្ចប់ហើយ ។ ស្ថានភាពក្នុងលោកីយ៍ជាទីសម្គាល់ចំពោះរឿងនេះ ។

សាវ័កប៉ុលបានមានប្រសាសន៍ថា: «ត្រូវឱ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ។
ដើម្បីនឹងបណ្ដាលឱ្យមានសេចក្ដីស្រឡាញ់ ហើយឱ្យប្រព្រឹត្តការល្អផង ឥតលែងប្រជុំគ្នា . . .
តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ ។ (ហេព្រើរ ១០:២៤, ២៥)
យើងសូមអញ្ជើញលោកអ្នកឱ្យអនុវត្តតាមដំបូន្មានរបស់សាវ័កប៉ុល ដោយរួមប្រជុំជាមួយនឹងយើងខ្ញុំ ។

តើលោកអ្នកចង់ឱ្យបុគ្គលណាម្នាក់មកជួបអ្នកទេ?

Copyright © 2004 Watchtower Bible and Tract Society of Pennsylvania. All rights reserved.